មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0097**

# សម្ភាសន៍ជាមួយឈ្មោះ សុខ គា ភេទប្រុស អាយុ៥៣ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«និរសា»

## រស់នៅភូមិម៉ៅ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:១៨:០១

## ២៥ទំព័រ

សុខ វណ្ណៈ ចឹងជាដំបូង ខ្ញុំសូមណែនាំខ្លួនថា ខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាពូណាស់ ។

សុខ គាៈ បាទ ។

សុខ វណ្ណៈ ខ្ញុំមកនេះដើម្បីចង់ដឹងរឿងរ៉ាវនៅក្នុងស្រុកភូមិនេះដែលកើតមានរឿងរ៉ាវជាច្រើនជំនាន់មកនេះ គឺចង់ឲ្យក្មេងជំនាន់ក្រោយបានដឹងពុថា ថាប្រទេសយើងបានជួបហេតុការណ៍ចេះមួយៗ ចឹងបទសម្ភាសន៍ខ្ញុំជាពូហ្នឹង តើពូអនុញ្ញាតឲ្យខ្ញុំសរសេរទុកឲ្យក្មេងជំនាន់ក្រោយបានដឹងទេ តើពូអនុញ្ញាតទេ?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងពូអនុញ្ញាត?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ?

សុខ គាៈ ខ្ញុំឈ្មោះ សុខ គា ។

សុខ វណ្ណៈ ពូអាយុប៉ុន្មានហើយ?

សុខ គាៈ អាយុ៥៣ ។

សុខ វណ្ណៈ ប្រពន្ធពូឈ្មោះអី?

សុខ គាៈ ឈ្មោះ សុខ លួត ។

សុខ វណ្ណៈ អាយុប៉ុន្មាន?

សុខ គាៈ អាយុ២៥ឆ្នាំ ។

សុខ វណ្ណៈ មានកូនប៉ុន្មាន?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

សុខ គា៖ ប្រពន្ធក្រោយអត់មានកូនទេ យកល្អដាក់ប្រពន្ធដើមវិញ។

សុខ វណ្ណៈ មិនអីទេ ប្រពន្ធណាក៏បាន ចឹងប្រពន្ធដើមមានកូនប៉ុន្មាន?

សុខ គា៖ មានកូនពីរ។

សុខ វណ្ណៈ ចឹងប្រពន្ធដើមឈ្មោះអី?

សុខ គា៖ ឈ្មោះ ចុង សួង។

សុខ វណ្ណៈ កូនប្រុសទាំងពីរឬយ៉ាងម៉េច?

សុខ គា៖ ស្រីមួយប្រុសមួយ។

សុខ វណ្ណៈ ឪពុកពូឈ្មោះអីដែរ?

សុខ គា៖ ឪពុកឈ្មោះ ម៉ែន សែន គាត់ជាទាហានសម័យលន់ នល់។

សុខ វណ្ណៈ ម្ដាយ?

សុខ គា៖ ម្ដាយឈ្មោះ ទុំ សាគិត។

សុខ វណ្ណៈ ចឹងសព្វថ្ងៃគាត់នៅរស់ដែលឬមួយយ៉ាងម៉េច?

សុខ គា៖ អត់ទេ អាពតវ៉ៃចោលហើយ។

សុខ វណ្ណៈ ចឹងបងប្អូនមានប៉ុន្មាននាក់?

សុខ គា៖ បងប្អូនមើល បងសាត បង សឿន និងខ្ញុំ មានបងប្អូនបួននាក់។

សុខ វណ្ណៈ ឥឡូវនៅរស់ប៉ុន្មាននាក់?

សុខ គា៖ ទេ បាត់ខ្លួនសម័យអាពត មិនដឹងជាទៅណាអស់ហើយ។

សុខ វណ្ណៈ ចឹងនៅសល់តែពូម្នាក់ឯងទេ?

សុខ គា៖ បាទ! ខ្ញុំជាកូនកំព្រា។

សុខ វណ្ណៈ ចឹងស្រុកកំណើតពូនៅណា?

សុខ គា៖ ស្រុកកំណើតខ្ញុំកើតនៅរតនៈគិរីនោះ ខ្ញុំវាវែងឆ្ងាយណាស់។

សុខ វណ្ណៈ បាទ!និយាយកន្លែងកើតតែម្ដង?

សុខ គា៖ កន្លែងកើតនៅរតនៈគិរី។

សុខ វណ្ណៈ ភូមិអីគេ?

សុខ គា៖ ដូវទៅបាក់អន្ទង់នេះ។

សុខ វណ្ណៈ ចឹងពូមានស្គាល់ភូមិទេ?

សុខ គារៈ ខ្ញុំភ្លេចអស់ហើយ ខ្ញុំចេញមកតាំងពីតូចនោះ នៅចំងាយពីរគីឡូផ្សារបាក់អន្ទង់មកផ្លូវអូរ យក្សឡោម ចេញពីផ្សារមកអូរយក្សឡោម ។

សុខ វណ្ណៈ ចឹងពូមានស្គាល់ឃុំទេ?

សុខ គារៈ ខ្ញុំភ្លេចហើយមិនបានចាំទេ ។

សុខ វណ្ណៈ ស្រុកអីគេ?

សុខ គារៈ ស្រុកក៏មិនបានដឹងដែរ ចាំតែខេត្តរតនៈគីរីហ្នឹង ផ្លូវអូរយក្សឡោម ។

សុខ វណ្ណៈ ឥឡូវពូនៅភូមិណា?

សុខ គារៈ នៅភូមិម៉ៅ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

សុខ វណ្ណៈ ចឹងជំនាន់ខ្មែរក្រហមនៅហ្នឹងគេហៅភូមិអី?

សុខ គារៈ ខ្ញុំជំនាន់ខ្មែរក្រហមខ្ញុំនៅពោធិសាត់ ។

សុខ វណ្ណៈ ចឹងពូមានដឹងទេ ថានៅភូមិនេះជំនាន់ខ្មែរក្រហមនៅខេត្តបាត់ដំបងឬយ៉ាងម៉េច?

សុខ គារៈ ខេត្តបាត់ដំបង ស្រុកថ្មពួក ។

សុខ វណ្ណៈ ចឹងនិយាយទៅឈ្មោះនេះតាំងពីសង្គមចាស់?

សុខ គារៈ បាទ!តាំងពីសង្គមចាស់ហើយ ខេត្តបន្ទាយមានជ័យមានខេត្តណា ទើបមកឥឡូវទេ កាល ហ្នឹងខេត្តបាត់ដំបងស្រុកថ្មពួក ។

សុខ វណ្ណៈ តែភូមិឃុំនៅដដែល?

សុខ គារៈ បាទ!ភូមិឃុំនៅដដែល ។

សុខ វណ្ណៈ ចឹងពូមានបានដឹងថា ដូរឈ្មោះនៅឆ្នាំណា?

សុខ គារៈ ទើបតែដូរឥឡូវដែរទេ កាលហ្នឹងឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានទេ ខ្ញុំភ្លេចហើយ ។

សុខ វណ្ណៈ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ថា កាលពីតូចពូរៀនដល់ណា ហេតុអីបានជាពូឈប់រៀនអីចឹង?

សុខ គារៈ និយាយប្រវត្តិខ្ញុំ កាលពីតូចនៅរតនៈគីរី កាលហ្នឹងមិនទាន់ដឹងក្តីប៉ុន្មានទេ ដល់ពេលនេះ គេវ៉ៃរតនៈគីរីហ្នឹងបែកអស់ កាលហ្នឹងអាមេរិចកាំងដឹកទៅស្រុកអាមេរិចកាំងណាស់ ខេត្ត រតនៈគីរីបែកហើយ អាហ្នឹងសម័យលន់ នល់ ។ ហ្នឹងខ្ញុំទាន់ក្តីអស់ហើយ ដល់នេះ អាមេរិចកាំងវាដឹកយកទៅដាក់ប្រទេសវា ដឹកយកទៅ ប្រទេសវាហើយបានដឹកទៅដាក់ ព្រៃនគរមិនស្រុកយួន ។ បានដឹកពីព្រៃនគរហ្នឹងមក កាលហ្នឹងឆ្លងសាឡាងមកចូលមក ដល់ភ្នំពេញមកនៅទួលគោកហ្នឹង ។

សុខ វណ្ណៈ ចឹងពូបានទៅដល់អាមេរិច?

សុខ គា: បាទ! ទៅដល់អាមេរិច ។

សុខ វណ្ណៈ នៅឆ្នាំណា?

សុខ គា: កាលហ្នឹងឆ្នាំ១៩៦០ជាង ឆ្នាំ៧០ខ្ញុំមកនៅភ្នំពេញហើយ ឆ្នាំ១៩៦៨ហ្នឹងហើយ ខ្ញុំនិយាយការពិត ។ កាលហ្នឹងគេដឹងពីរតនៈគិរីមក អាដាកាតាទេណាស់ ។

សុខ វណ្ណៈ ចឹងនៅឆ្នាំ១៩៦៨ អាមេរិចកាំងដឹកប្រជាជនទាំងអស់នៅខេត្តរតនៈគិរី?

សុខ គា: បាទ! កាលវើរតនៈគិរីបែកអស់នោះ ហើយទាហានឡើងមកមុនទៀត ។

សុខ វណ្ណៈ ចឹងដឹកកាលហ្នឹងយកតែប្រពន្ធទាហានទេឬយកប្រជាជនទៀត?

សុខ គា: ដឹកយកទាំងអស់ហ្នឹង ដឹកមួយខេត្តរតនៈគិរីហ្នឹង ។

សុខ វណ្ណៈ ចឹងទៅដល់អាមេរិចទាំងគ្នាមួយខេត្តហ្នឹង?

សុខ គា: ទាំងអស់ហ្នឹង ចុះកាលហ្នឹងអាមេរិចវាជួយនោះ កាលនោះសម័យលន់ នល់ ខ្ញុំនិយាយតែការពិតទេ ។

សុខ វណ្ណៈ ចឹងប្រទេសអាមេរិច?

សុខ គា: បាទ ។

សុខ វណ្ណៈ ចឹងក្រោយមកបញ្ជូនប្រជាជនទាំងអស់មកវិញ?

សុខ គា: បញ្ជូនមកវិញ កាលហ្នឹងដឹកយន្តហោះអាដាកាតា កន្លាប្អូនទៅចុះនៅព្រៃនគរ ទៅដល់ព្រៃនគរហ្នឹងចំនួនមួយអាទិត្យ កាលហ្នឹងទាហានអាមេរិចកាំងវាមិននៅហ្នឹង ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ១៩៦៨ហ្នឹងដឹកប្រជាជនទាំងអស់ហ្នឹងមិនមែនទៅអាមេរិចទេ ទៅព្រៃនគរទេចឹង?

សុខ គា: ទៅអាមេរិច ។

សុខ វណ្ណៈ ចឹងទៅអាមេរិចសិនទី១?

សុខ គា: បាទ ។

សុខ វណ្ណៈ ចឹងដឹកទៅអាមេរិចបានប៉ុន្មានថ្ងៃបានមកព្រៃនគរវិញ?

សុខ គា: ទេ កាលហ្នឹងខ្ញុំដូចជាច្រឡំដែរ មិនដឹងថាទៅអាមេរិចឬទៅព្រៃនគរ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងប្រហែលជាទៅព្រៃនគរហើយ?

សុខ គា: បាទ! ព្រោះឃើញទាហានអាមេរិចនៅនោះឯង ប្រហែលជាព្រៃនគរហើយ ។

សុខ វណ្ណៈ ចឹងនៅព្រៃនគរហ្នឹងបានប្រហែលជាប៉ុន្មាន?

សុខ គា: កាលហ្នឹងនៅយូរដែរ ប្រហែលជាកន្លះខែទៅមួយខែប៉ុណ្ណឹងឯង កាលហ្នឹងគ្រាន់តែដឹកទៅ

សង្គ្រោះយើងហើយបានបញ្ជូនយើង ។

សុខ វណ្ណៈ ចឹងក្រោយមកបញ្ជូនមកភ្នំពេញវិញ?

សុខ គា: បាទ!បញ្ជូនមកភ្នំពេញវិញតាមកប៉ាល់ទេ មកឈប់នៅទួលគោក នៅទួលគោកបានជាពីរខែគេយកទៅនៅកំពង់ក្រទួតខេត្តកណ្ដាលនោះ ចាំកន្លែងនោះទៀត ។

សុខ វណ្ណៈ ចឹងបញ្ជូនមកកំពង់ក្រទួតហើយខាងអាមេរិចហ្នឹងបានបញ្ជូនមកខេត្តរតនៈគិរីវិញទេ?

សុខ គា: អត់ទេ ។

សុខ វណ្ណៈ ចឹងប្រជាជននៅភ្នំពេញទាំងអស់?

សុខ គា: កាលហ្នឹងគេដឹកប្រជាជនមកអស់ហើយបានគេដឹកទាហានម្ដង ។

សុខ វណ្ណៈ ដឹកទាហានទៅខាងណាវិញ?

សុខ គា: ដឹកទាហានមកចុះព្រៃនរគដែរ ហើយឪពុកខ្ញុំមកតាមរកម៉ែខ្ញុំនៅខេត្តកណ្ដាល ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានទាំងជនជាតិអី ត្រូវមកទាំងអស់?

សុខ គា: ជនជាតិមិនដឹងជាយ៉ាងណា ខ្ញុំមកមុន គេដឹកមកមួយអាទិត្យជាងហើយបានដល់ប៉ាត់តាយ៉ុងឪពុកខ្ញុំ កាលហ្នឹងឪពុកខ្ញុំពាក់សក្ដិធំដែរ ។

សុខ វណ្ណៈ ចឹងឪពុកពូទាហានអាមេរិចចឹង?

សុខ គា: បាទ! កាលហ្នឹងជាទាហានលន់ នល់ គាត់ពាក់សក្ដិ២ ដល់ក្រោយមកទៀតពាក់សក្ដិ៣ គាត់មានកូនទាហានច្រើនណាស់ ឪពុកខ្ញុំមាខធំណាស់ ។

សុខ វណ្ណៈ ចឹងកាលកើតរដ្ឋប្រហារនៅឆ្នាំ១៩៧០ពូនៅណា?

សុខ គា: ចាំខ្ញុំរៀបរាប់ទៀត កាលហ្នឹងខ្ញុំតាមឪពុកខ្ញុំទៅមកៗនៅតាំងគោក កាលហ្នឹងគេយកទាហាន គាត់ហ្នឹងទៅដាក់នៅតាំងគោក កាលហ្នឹងលោកតា អ៊ឹ សាវុធពាក់សក្ដិ៥ ។

សុខ វណ្ណៈ បាទ ។

សុខ គា: ឪពុកខ្ញុំហ្នឹង មេគាត់ឈ្មោះតា អ៊ឹ សាវុធពាក់សក្ដិ៥ បើរៀបរាប់ទៅអ្នកធំដឹងទាំងអស់ ។

សុខ វណ្ណៈ បាទ ។

សុខ គា: បើអ្នកធំកាលសេរីហ្នឹង និយាយប៉ុណ្ណឹងទៅគេដឹងហើយ លោកតា អ៊ឹ សាវុធពាក់សក្ដិ៥ក៏ គេស្គាល់ហើយ ។

សុខ វណ្ណៈ ឪពុកពូឈ្មោះអី កាលហ្នឹង?

សុខ គា: ឈ្មោះ ម៉ែន សែនហ្នឹង ។

សុខ វណ្ណៈ ចឹងអ៊ឹ សាវុធពីណាគេ?

សុខ គា: ហ្នឹងជាមេរបស់គាត់ ។

សុខ វណ្ណៈ ចឹងកាលនៅតាំងគោកហ្នឹងយ៉ាងម៉េច?

សុខ គា: នៅតាំងគោកហ្នឹង គេវ៉ៃគ្នាចុះឡើងៗ ខ្ញុំកាលនៅក្រោយពេទ្យមន្ទីរវង្សណាស់ ។

សុខ វណ្ណៈ តែពូកាលហ្នឹងមិនទានចូលធ្វើជាទាហានទេ?

សុខ គា: ខ្ញុំកាលហ្នឹងនៅជាកូនក្មេងនៅឡើយ ខ្ញុំកាលហ្នឹងអាយុប្រហែលជា១៣ទៅ១៨ហើយ ។

សុខ វណ្ណៈ បាទ ។

សុខ គា: កាលហ្នឹងឪពុកខ្ញុំវ៉ៃនៅតាំងគោកខ្លាំងហើយ ម្តាយខ្ញុំនៅក្រោយពេទ្យមន្ទីរវង្ស គេឲ្យប្រពន្ធទាហាននៅក្រោយពេទ្យមន្ទីរវង្សគេមានបន្ទាយមួយ ខ្ញុំកាលហ្នឹងមួយខែទៅបើប្រាក់ខែម្តងទៅបើកនៅតាំងគោកនោះហើយឪពុកខ្ញុំមិនបានមកទេ ច្បាំងគ្នាខ្លាំងណាស់ កាលឆ្នាំ៧០-៧៣-៧៤វ៉ៃគ្នាខ្លាំងណាស់ ខ្ញុំជួនអីទៅបើប្រាក់ខែតាមឡានគេ កាលហ្នឹងឪពុកមិនឲ្យទៅ ទេ តែខ្ញុំបេះតែរត់តាមឡានដល់ទៅដល់ឪពុកខ្ញុំប្រាប់កូនទាហានគាត់ថា ឯងថ្ងៃក្រោយ កុំកូនអញតាមមក ។

សុខ វណ្ណៈ តាមខ្ញុំដឹងកាលច្បាំងនៅតាំងគោកបាញ់គ្នាខ្លាំងណាស់?

សុខ គា: តាមផ្លូវមានឃើញបាញ់ឡានបេះអីហ្នឹង គាត់ខ្លាចខ្ញុំស្លាប់ខ្លាចមានគ្រោះថ្នាក់ គាត់បេះតែដេកូនទាហានគាត់ ។

សុខ វណ្ណៈ បាទ ។

សុខ គា: កូនទាហានប្រាប់គាត់វិញថា ឲ្យខ្ញុំធ្វើយ៉ាងម៉េចចេញមករត់តាមឡានហើយ ។

សុខ វណ្ណៈ ចឹងខ្ញុំចង់ដឹងថា ហេតុអីបានជាអាមេរិចប្រមូលប្រជាជននៅខេត្តរតនៈគិរីទាំងអស់?

សុខ គា: ដោយសារតែសង្គ្រាម កាលហ្នឹងគេហៅយក្សកុងឆ្មេញខ្មៅអីគេនោះ បាញ់គ្នាខ្លាំងមានយន្តហោះអីហ្នឹង កាលហ្នឹងខ្ញុំនៅកូនក្មេងមិនសូវបានដឹងទេ តែរឿងច្បាំងគ្នាច្បាំងហើយណាស់ កាលនោះកុំអាមេរិចដឹកមកវ៉ៃបែករតនៈគិរីណាស់ ។

សុខ វណ្ណៈ ចឹងរឿងហ្នឹងដោយសារតែសង្គ្រាម?

សុខ គា: បាទ ។

សុខ វណ្ណៈ ចឹងពូនិយាយសមក្មុភាពនៅតាំងគោកពេលវ៉ៃហ្នឹងវាយ៉ាងម៉េចខ្លះទៅ?

សុខ គា: រឿងតាំងគោកគ្រួសារខ្ញុំអត់មាននៅហ្នឹងទេ នៅតែឪពុកខ្ញុំជាទាហានណាស់ ។

សុខ វណ្ណៈ ចឹងពូនៅក្រោយពេទ្យមន្ទីរវង្ស?

សុខ គា: ខ្ញុំនៅក្រោយពេទ្យមន្ទីរវង្សខ្ញុំរៀនផង ទៅបើប្រាក់ខែកន្លែងឪពុកខ្ញុំផង ។

សុខ វណ្ណៈ  កាលហ្នឹងពូរៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

សុខ គា:  ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១“ចាស់” ។

សុខ វណ្ណៈ  ចឹងរៀនបានបន្តិចហ្នឹង?

សុខ គា:  បានរៀនបានតែបន្តិចហ្នឹង ដល់រៀនផុតពីហ្នឹងមកខ្ញុំមានអឺមួយទៀត កាលហ្នឹងខ្ញុំទៅផ្សារថ្មីវង្វេងនៅឯនោះ កាលហ្នឹងខ្ញុំឆ្ងល់ខ្ញុំនៅក្រោយមន្ទីរពេទ្យមន្ទីរវង្សប៉ុន្មានឆ្នាំហើយ យ៉ាងម៉េចបានត្រូវវង្វេង ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  ដល់ពេលវង្វេង បែបវង្វេងឲ្យជួបអឺដឹង ហើយហ្នឹងត្រូវជាបងប្អូនជីដូនមួយម៉ែខ្ញុំហ្នឹង ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  គាត់នៅកំពង់ឆ្នាំង ដល់វង្វេងបានជួបអឺ ដល់បានជួបអឺទៅអឺយកមកកំពង់ឆ្នាំង អឺហ្នឹងក៏អ្នកធំទៀត គាត់នៅជិតព្រលានយន្តហោះកំពង់ឆ្នាំង ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  គាត់ឈ្មោះទី ជា ប្រពន្ធគាត់ឈ្មោះទុំ សាវុន ម៉ែខ្ញុំឈ្មោះ ទុំ សាគិត ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  ហើយប្តីគាត់ពាក់សក្តិមួយនៅព្រលានយន្តហោះណាស់ ដល់ពេលនេះទៅអឺខ្ញុំប្រាប់ថាមានពូឯងមួយទៀតបាក់សក្តិ៤នៅពោធិសាត់ ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  ត្រូវជាពូបង្កើតខ្ញុំ នៅជិតរាហូរហែកមាត់មានដែលឃើញទេ នៅពោធិសាត់មាននៅសព្វថ្ងៃ គេហៅជិតបន្ទាយស៊ុប ។

សុខ វណ្ណៈ  បាទ ។

សុខ គា:  គេហៅកុមារស្តេចពីដើម គេហៅទាហានអង់វង់ទ្រុប គេហៅថាទាហានកំព្រា ទាហានសម្តេច ខ្ញុំក៏នៅជាមួយពូហ្នឹងឯង ។

សុខ វណ្ណៈ  ចឹងនៅពេលខ្មែរក្រហមវ៉ៃចូលភ្នំពេញនៅឆ្នាំ១៩៧៥ តើពូមានដឹងថាគ្រួសារពូជម្លៀសចេញទៅខាងណាវិញ?

សុខ គា:  នៅពេលនោះគ្មានពីណាជួយអ្នកណាបានដែរ ដឹងថាឪពុកជាទាហាននៅតាំងគោកមែនប៉ុន្តែដឹងថាឪពុកទាហានហើយ តែកាលហ្នឹងខ្លាចគាត់ចាញ់ខបាយកលថាទៅទទួលសម្តេចចឹងណាស់ កាលហ្នឹងគេថាឲ្យទៅទទួលសម្តេច ។

សុខ វណ្ណៈ កាលឆ្នាំ៧៥ហ្នឹង?

សុខ គាៈ បាទ! កាលដែលខ្មែរក្រហមចូលហ្នឹងណាស់ កាលហ្នឹងគេថាអ្នកធំពាក់សក្តិប៉ុន្មានមិនបាច់ភ័យភិតទេ នៅដដែលចាំគេឲ្យឡើងធំវិញ តែខ្លាចឪពុកខ្ញុំចាញ់ខបាយកលគេយកឪពុកខ្ញុំទៅសម្លាប់ខ្ញុំមិនបានដឹងត្រង់ហ្នឹង ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ កាលនោះអ្នកធំតូចប្រាប់ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានមនុស្សមួយចំនួនសារភាព?

សុខ គាៈ បាទ! ហើយកាលហ្នឹងគេយកទៅវៃចោលច្រើនណាស់ ដូចបងឯងគេប្រាប់ថាធំនៅតែចេះហើយ ដល់យើងទម្លាក់អាវុធចេះទៅ គេយកយើងបាត់ហើយមិនដឹងជាយកទៅខាងណា សូម្បីតែម្តាយខ្ញុំបាត់ឈឹង ។

សុខ វណ្ណៈ ចឹងប្រហែលជាឪពុកពូហ្នឹងបានប្រាប់គេ?

សុខ គាៈ បាទ!បាត់ខ្ញុំមិនដែលបានជួបទេ ដល់ពេលខ្ញុំនៅដើរបាននេះ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៧៥មិនបានជួបឪពុកទេ?

សុខ គាៈ អត់ទេ អឺក៏បែកអស់ហើយ ពូក៏បែកទៀត ថាអស់ទាំងអស់មិនមាន ។

សុខ វណ្ណៈ ចឹងកាលហ្នឹងខ្លាចទាហានខ្មែរក្រហមស្គាល់គេសម្លាប់តែម្តង?

សុខ គាៈ ទាហានកាលហ្នឹងវាដឹ ព្រោះទាហានតាំងគោកនិងទាហានកោះក្រឡ មិនសាកទេឲ្យដាក់កាំភ្លើងហ្នឹងមិនងាយទេ ។

សុខ វណ្ណៈ ចឹងបាត់ខ្លួនទាំងអស់ ។

សុខ គាៈ ខ្ញុំខ្លាចចាញ់ខបាយកលខ្មែរក្រហមគេយកទៅសម្លាប់ចោល ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៧៥ពូមិនបានទៅជួបឪពុកម្តាយបងប្អូនទេ?

សុខ គាៈ ខ្ញុំបែកគាត់ទាំងអស់ ។

សុខ វណ្ណៈ ហេតុអីបានបែកម្តាយដែរ?

សុខ គាៈ ចុះខ្ញុំមកពីភ្នំពេញមិនមកនៅជាមួយអឺ កាលហ្នឹងមិនពូថាខ្ញុំវង្វេងហ្នឹងផ្សារថ្មីហ្នឹង ដល់វង្វេងទៅជួបអឺ ខ្ញុំនៅភ្នំពេញរាប់ឆ្នាំហើយយ៉ាងម៉េចបានត្រូវវង្វេង ដល់ជួបអឺទៅអឺយកមកនៅកំពង់ឆ្នាំង ដល់អឺខ្ញុំប្រាប់ថាមានពូឯងម្នាក់ទៀតនៅពោធិសាត់ ដល់ខ្ញុំមកនៅជាមួយពូ ។

សុខ វណ្ណៈ ចឹងពូមកនៅកំពង់ឆ្នាំងតាំងពីឆ្នាំណា?

សុខ គា៖ មកកាលឆ្នាំ៧៨ ដល់៧៩ បែកម៉ែបាត់ហើយ ។

សុខ វណ្ណៈ ចឹងនៅពេលដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ពូមានបានដឹងថាឪពុកម្ដាយនិង បងប្អូនបីនាក់ទៀតទៅនៅណាទេ?

សុខ គា៖ អត់ដឹងទេ មិនបានដឹងទាំងអស់ ខ្ញុំឃ្លាតឆ្ងាយហើយ ចុះឪពុកនៅតាំងគោក ម៉ែនៅភ្នំពេញនោះ ខ្ញុំមកនៅពោធិសាត់ហើយ បែកឆ្ងាយអស់ហើយអត់មានដឹងដំណឹងអីកាលសម័យ អាពតមានដែលទៅរកណាឃើញមានដិះឡានដើររកណា ។ នៅឃុំណាឃុំហ្នឹងហើយស្រុក ណាស្រុកហ្នឹងហើយ ភូមិណាភូមិនោះហើយចេញមិនបានទេ ។

សុខ វណ្ណៈ ចឹងនៅពេលស្រុកស្រួលបួលពូមិនទៅរកនៅស្រុកកំណើតវិញ លោកឃើញគាត់?

សុខ គា៖ ខ្ញុំទៅម្ដង ខ្ញុំប្រហែល១ដឺខ្ញុំហើយ ខ្ញុំតែឯងផងខ្ញុំខ្វាចគេថា ឯងសើរើអីវែងចោល ។

សុខ វណ្ណៈ ចឹងសម័យឥឡូវដែលជឿនលឿនហើយនេះ ពូមានដែលទៅទេ?

សុខ គា៖ សម័យជឿនលឿនហើយខ្ញុំមិនបានទៅទេ ព្រោះខ្ញុំពិការហើយ កាលចុងកន្ទុយវៀតណាម ដកចេញអស់ទៅកាលហ្នឹងខ្ញុំនៅស្វាយចេក នៅតែជំនាញការមួយៗ កាលហ្នឹងទៅរកម្ដងដែរ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៩០ជាងនេះ យើងបោះឆ្នោតហើយហ្នឹង?

សុខ គា៖ អត់បានទៅទាំងអស់ ខ្ញុំធ្លាក់ខ្លួនពិការអស់ហើយ ។

សុខ វណ្ណៈ ចឹងពូគួរតែទៅស្រុកកំណើតម្ដងទៀត ក្រែងលោបានដឹងពីម្ដាយនិងបងប្អូនបីនាក់ទៀតណាស់?

សុខ គា៖ បាទ ។

សុខ វណ្ណៈ ចឹងដល់ពូមិនបានទៅចឹង មិនដឹងថាម្ដាយបាត់ខ្លួននៅសម័យខ្មែរក្រហមឬយ៉ាងណា?

សុខ គា៖ ឥឡូវហ្នឹងវាពិបាករឿងខ្ញុំដើរ ណាមួយខ្ញុំមានកូនស្រីមួយនៅបឹងកកទៀត សព្វថ្ងៃខ្ញុំមានប្រពន្ធមួយនិងកូនមួយនៅរៀនផ្កាំ ណាមួយរឿងដើរហើរវាពិបាកណាស់ វាអស់មួយកំណាត់ចង្កេះហើយ វាពិបាកជិះឡានអីហ្នឹង ខ្ញុំទៅតែត្រឹមស្វាយទេ គេឲ្យបើកប្រាក់បន្តិចបន្តួចហ្នឹងយ៉ាបដង ។

សុខ វណ្ណៈ ចឹងពូមិនអាចដើរបាន?

សុខ គា៖ អត់បានទេ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៧៥ពូថាខ្មែរក្រហមចិត្តល្អយ៉ាងម៉េច?

សុខ គា: កាលហ្នឹងនៅពេលខ្មែរក្រហមជម្លៀសចេញពីពោធិសាត់ហ្នឹងមក គេហៅអីខ្នារទទឹង បឹងខ្នារ តែនៅក្នុងខេត្តពោធិសាត់ដដែរ ។

សុខ វណ្ណៈ: ជម្លៀស?

សុខ គា: ជម្លៀសមកបឹងខ្នារ ។

សុខ វណ្ណៈ: ចឹងបឹងខ្នារហ្នឹងនៅខេត្តពោធិសាត់?

សុខ គា: បាទ! បឹងខ្នារខេត្តពោធិសាត់ត្រពាំងជងហ្នឹង ។

សុខ វណ្ណៈ: ចឹងនៅបឹងខ្នាររហូត?

សុខ គា: បាទ! កាលដែលជម្លៀសមកខ្មែរក្រហមមានគ្នាប្រហែលជា៩នាក់ មេហ្នឹងខ្មៅឈ្មោះ តាឆេង ហើយខ្ញុំកាលហ្នឹងគេដេញមក គេដេញចេញពីពោធិសាត់ កាលនោះប្រហែលជាម៉ោង៩ជាង ខ្មែរក្រហមចូល ។

សុខ វណ្ណៈ: បាទ ។

សុខ គា: ចឹងចេះតែដើរមករហូតដល់បឹងខ្នារ គេហ្នឹងគេជាសម្រាក កាលហ្នឹងគេមានម៉ែឪលាន់ គេរ៉ែក ខ្ញុំមានអីមានតែខោអាវមួយចង្កេះ ហើយខ្ញុំកាលហ្នឹងជាទាហានសម្តេចផង ។

សុខ វណ្ណៈ: តែពូលាក់មិនហ៊ានប្រាប់គេទេ?

សុខ គា: ខ្ញុំមិនទាន់ប្រាប់ទេ កាលហ្នឹងខ្មែរក្រហមស្រែកប្រាប់ថា ញោមៗសម្រាក ដល់ពេលសម្រាកទៅបាយហូប ខ្ញុំអត់មានបានដាំទេ ដល់ខ្មែរក្រហមបីបួននាក់ហ្នឹងគេមានបាយដាក់ក្រមែលតាមខ្លួនចឹងទៅ ដល់ពេលគេហូបបាយលាន់ខ្មែរក្រហមមេហ្នឹងណាស់ ឈ្មោះតាឆេងហ្នឹង ឃើញខ្ញុំគាត់ថាចុះអាអូននោះមិនហូបបាយនិងគេ ។ ខ្ញុំថាខ្ញុំមិនមានបាយហូបទេ ចុះយ៉ាងម៉េចបានជាមិនមានមេនោះសួរថា អីណាបងប្អូន ខ្ញុំថាបងប្អូននៅពោធិសាត់ នៅកំពង់ឆ្នាំងឯនោះ ខ្ញុំមកលេងនិងពូនៅពោធិសាត់ មិនមានបងប្អូនដាំបាយអីទេ ដល់ហើយគាត់ប្រាប់កូនទាហានគាត់ថា មិត្តឯងឲ្យអាអូននោះហូបបាយផង ។ ដល់ពេលហូប បាយហើយ ខ្ញុំក៏យកចិត្តគេ ចុះចាប់ពីហ្នឹងមកខ្ញុំជាកូនកំព្រាហើយ ។

សុខ វណ្ណៈ: បាទ ។

សុខ គា: ខ្ញុំចេញពីពូទៀត ខ្ញុំក្លាយជាកូនកំព្រាមែនទែនហើយ ចឹងបានជាខ្មែរក្រហមឈ្មោះតាឆេង ឲ្យហូបបាយអីទៅ ខ្ញុំថាពូឲ្យខ្ញុំជួយកាន់អានេះអានោះទៅមិនហ៊ានហៅលោកទេហៅពូ ខ្ញុំយកចិត្តគេ ដល់ចឹងទៅគេឲ្យខ្ញុំកាន់អានេះកាន់អានោះចឹងទៅ កាលហ្នឹងខ្ញុំប្រាប់គេថា លោកពូអើយយ៉ាងណា ជួយយកអាសាខ្ញុំផង ខ្ញុំមិនមានម៉ែឪទេ ។ កាលហ្នឹង

ខ្ញុំនិយាយស្រក់ទឹកភ្នែកខ្ញុំនៅតូចនោះ ពួងឲ្យខ្ញុំធ្វើអីក៏ខ្ញុំធ្វើដែរ ឲ្យតែខ្ញុំបានរស់ផង ដល់ចឹងគាត់ យកខ្ញុំរហូត ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ ហើយសម័យខ្មែរក្រហមហ្នឹងគាត់យកខ្ញុំធ្វើនិរសា កាលហ្នឹងយើងរួមរស់នៅជាមួយគេ កាលហ្នឹង គេយកខ្ញុំធ្វើនិរសារហូត ។

សុខ វណ្ណៈ ចឹងយកធ្វើជានិរសាតាំងពីឆ្នាំ៧៥មក?

សុខ គាៈ បាទ!តាំងពីឆ្នាំ៧៥ហ្នឹងមករហូត ។

សុខ វណ្ណៈ ចឹងគាត់ទៅណាយើងទៅហ្នឹងដែរ?

សុខ គាៈ បាទ!គេប្រើខ្ញុំមួយយប់ៗមិនដែលឈប់ទេ

បន្តិចទៅបឹងខ្នារបន្តិចទៅនោះទៅខ្នារទទឹងបន្តិច ទៅ ទៅម៉ាលិច ។

សុខ វណ្ណៈ ចឹងកាលនិរសាហ្នឹងគេឲ្យធ្វើអីខ្លះ?

សុខ គាៈ និរសាហ្នឹងមានបានធ្វើអីទេ គ្រាន់តែដើរឃ្វាលគោមើលសេះអីហ្នឹង មើលផ្ទះសំបែងគេ ហើយគេប្រើយើងទៅនេះម្តងៗអី ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានរត់សំបុត្រអីទេ?

សុខ គាៈ បាទ!មានរត់សំបុត្រឲ្យមេៗដែរ ។

សុខ វណ្ណៈ ចឹងមានហ៊ានបើកមើលសំបុត្រហ្នឹងទេ?

សុខ គាៈ មិនហ៊ានទេ មិនដឹងជាគេដាក់យ៉ាងម៉េចមិនដែលហ៊ាន បើហ៊ានងាប់ហើយគេឲ្យទៅដើងៗ ហើយ គេឲ្យទៅត្បូងៗហើយ ។

សុខ វណ្ណៈ តែកាលហ្នឹងរត់សំបុត្រតែនៅក្នុងខេត្តទេ?

សុខ គាៈ បាទ!នៅក្នុងខេត្តទេ ។

សុខ វណ្ណៈ មានដែលបានទៅដល់ភ្នំពេញទេ?

សុខ គាៈ មិនដែលទេ ។

សុខ វណ្ណៈ ចឹងពូនៅជាមួយ តា ឆេង ដល់ពេលណា?

សុខ គាៈ ខ្ញុំនៅជិតដល់ពេលវៀតណាមចូល កាលហ្នឹងតា ម៉ុកមកថា លោកឯងទាំងអស់គ្នាអ្នកណាមាននិរសាអីតា ម៉ុកយកទាំងអស់ លោកណាមិត្តណាហ៊ានទុកមិនបានទេ ខ្ញុំកាលហ្នឹងគេឲ្យកាន់កាំភ្លើងហើយពេលហ្នឹង ។

សុខ វណ្ណៈ ចឹងជិតវៀតណាមចូលមានតែឆ្នាំ៧៨?

សុខ គាៈ បាទ!ឆ្នាំ៧៨ ។

សុខ វណ្ណៈ ចឹងតា ម៉ុក ប្រកាសថាឲ្យនិរសាទាំងអស់មកគាត់?

សុខ គាៈ បាទ! តា ម៉ុកប្រមូលទាំងអស់ម៉ាខេត្តពោធិសាត់ ។

សុខ វណ្ណៈ ចឹងតា ឆេងមេរបស់ពូត្រូវគេចាប់ខ្លួនចឹង?

សុខ គាៈ គេអត់មានចាប់ទេ តា ម៉ុកគ្រាន់តែថានិរសាឯងឲ្យមកអញ ។

សុខ វណ្ណៈ ចឹងតា ឆេងទៅណាវិញ?

សុខ គាៈ តា ឆេង មិនដឹងជាទៅខាងណាខាងណីទៀត នៅលើគេខ្ញុំមិនបានដឹងទេ បែកគ្នាអស់ ។

សុខ វណ្ណៈ ចឹង តា ឆេងបាត់ខ្លួនរហូតតា ឆេង?

សុខ គាៈ មិនបាត់ទេ មិនដឹងជាទៅណា មិនដឹងជាគេឲ្យគាត់ទៅកាន់អីទៀតខ្ញុំមិនដឹង ខ្ញុំតាម៉ុករៀប កំលាំងមកនៅតាមគេផ្សេង ។

សុខ វណ្ណៈ ចឹងនៅពេលដែលតា ម៉ុក និយាយចឹងលែងបានជួបតា ឆេងហើយ?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងលែងឃើញតា ឆេងរហូតដល់សព្វថ្ងៃនេះ?

សុខ គាៈ កាលហ្នឹងមុនហ្នឹងបែកគ្នាគាត់ថា ចេះឯងយកមាសមួយខ្សែទៅ តែមាសហ្នឹងមិនដឹង ប៉ុន្មានទេថាធំដែរ ប្រហែលជាប្រាំជីជីង បើយ៉ាងណាឯងទុកមាសហ្នឹងចាយទៅ ឯងចាប់ ពីថ្ងៃនេះទៅលែងបានជួបអញហើយ ព្រោះគេយកអញទៅធ្វើកង់ទ័ពហើយ លែងបាន នៅនិរសាជុំអញហើយ កាលហ្នឹងប្រជាជនក៏ធ្វើដែលឲ្យតែជាប់ខ្សែគេយកទៅហើយរឿង ខ្ញុំ បើនិយាយវាវែងណាស់ គាត់ថាស្រុកស្រួលទុកចាយទៅ ឯងមិនបានជួបអញវាមិន បាន មែនហ្នឹងឯង ។

សុខ វណ្ណៈ ចឹងតា ឆេងហ្នឹងគាត់ចិត្តល្អទេ?

សុខ គាៈ បាទ!គាត់ចិត្តល្អណាស់ ណានៅជាមួយគាត់គាត់ជួយទាំងអស់ កងភ្លូរនៅជាមួយគាត់ ស្រួលណាស់ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ តា ឆេង ហ្នឹងខ្មៅទាប ដូចថាខាងកងភ្លូរមាន២០០ចេះទៅ គាត់ដាក់ថា២៥០អីនោះ ។

សុខ វណ្ណៈ បាទ ។

សុខ គា:	បើកងស្នួងមាន៣០០ចេះ គាត់ដាក់ថាមាន៣៥០ គាត់មិនហ៊ានដាក់ច្រើនទេ ខ្លាចមេលើដែរ ចឹងបានថាពីណាក៏ចង់នៅជាមួយតាឆេងដែរ គាត់ខ្មែរក្រហមធំដែរ ជាប្រធានវរៈសេនាធំ ។

សុខ វណ្ណៈ	ចឹងកាលនៅជាមួយ តា ឆេង ការហូបចុកមិនដែលខ្វះទេ?

សុខ គា:	មិនដែលខ្វះទេ កាលខ្ញុំនៅចឹងខ្លារហ្នឹងនៅជាប់រោងម៉ាស៊ីន ហើយជាប់វ៉ារថភ្លើងទៀត ។

សុខ វណ្ណៈ	បាទ ។

សុខ គា:	ដល់ពេលចឹង តា ឆេង គាត់ថា អា គា តាមពិតខ្ញុំឈ្មោះ អាបារាំងទេ តែកាលជំនាន់ លន់ នល់ ខ្ញុំស៊ីឈ្មោះទាហានពាក់សក្តិ១ដែលងាប់ទៅ ។

សុខ វណ្ណៈ	ចឹងពូស៊ីឈ្មោះទាហាន លន់ នល់?

សុខ គា:	បាទ! ខ្ញុំមានឈ្មោះទាហាន លន់ នល់នៅអាមេរិចទៀតនោះឈ្មោះខ្ញុំ ។

សុខ វណ្ណៈ	ចឹងកាលហ្នឹងអត់មានហ៊ានប្រាប់តា ឆេងថាជាទាហានលន់ នល់ទេ?

សុខ គា:	បើនិយាយទៅវែងជាងនេះទៀត កាលហ្នឹងគេយកខ្ញុំវៃចោលដែរ តែបានតា ឆេង ហ្នឹងហើយជួយ ។

សុខ វណ្ណៈ	ចឹងតា ឆេង ដឹងថាពូជាទាហាន លន់ នល់?

សុខ គា:	គាត់ដឹង កាលហ្នឹងគេចង់ចាប់ខ្ញុំ តា ឆេងយកខ្ញុំទៅលក់កងចំការទៀត ។

សុខ វណ្ណៈ	ឆ្នាំណា?

សុខ គា:	ឆ្នាំជិតវៀតណាមចូលដែរ កាលហ្នឹងគេស្រាវជ្រាវទៅដឹងថាខ្ញុំហ្នឹងធ្វើទាហានលន នល់ហើយឪធ្វើធំទៀត ។

សុខ វណ្ណៈ	ចឹងប្រហែលជាឆ្នាំ១៩៧៧?

សុខ គា:	បាទ!ប្រហែលជាឆ្នាំ៧៧ហើយ ប្រហែលជាមួយឆ្នាំទៀតអី ជិតមួយឆ្នាំទៀតវៀតណាមចូលហើយ ។

សុខ វណ្ណៈ	ចឹងកាល៧៨តា ឆេងឈប់នៅហើយ ។

សុខ គា:	ខ្ញុំនៅជុំគាត់រាល់ថ្ងៃដល់ថ្ងៃមួយនោះ មានឈ្មោះពុំមួយនោះ អាពុំប្រាប់ថា អា គាគេយកឯងវៃចោលហើយ ខ្ញុំថាថីបានជាយកខ្ញុំវៃចោល ចុះឯងជាប់អតីតម៉ែឪអ្នកធំ ខ្ញុំកាលហ្នឹងពុថា យកវៃចោលខ្ញុំភ័យលែងហូបបាយ ។

សុខ វណ្ណៈ	ចឹងគេសួរតាមពីណាបានដឹងថាពូធ្វើទាហានលន់ នល់ហ្នឹង?

សុខ គា:	កាលហ្នឹងខ្ញុំប្រាប់តា ឆេងអីនោះ តា ឆេងនោះប្រហែលជាគាត់រាយការណ៍ទៅដែលដឹង គាត់ប្រាប់គេត្រង់ចឹងបានចុះ ឈ្មោះពុំហ្នឹងប្រាប់ខ្ញុំបានប្រហែលជាមួយម៉ោង តា ឆេង មកដល់ប្រាប់ខ្ញុំថាចេះ គាត់ជិះសេះមកគាត់ថាអាគាឯង កាលហ្នឹងខ្ញុំដឹងខ្លួនមុនហើយនោះ ខ្ញុំថាខ្ញុំមានកំហុសអី ឯងជាប់អតីតឪអ្នកធំនោះ ។

សុខ វណ្ណៈ	ចឹងកាលហ្នឹងតា ឆេងមកទាន់?

សុខ គា:	តា ឆេងមកទាន់ តា ឆេងប្រាប់ថា អា គាឯងព្រមតាមអញអត់ ខ្ញុំថាបងឯងឲ្យខ្ញុំចូល រន្ធក្តាមក៏ខ្ញុំចូល ខ្ញុំនៅជាមួយបងឯងតាំងពីប៉ុន្មានឆ្នាំមកហើយ ខ្ញុំមិនដែលប្រកែកបងឯង យ៉ាងណាទេ បងឯងឲ្យខ្ញុំទៅណាក៏ខ្ញុំទៅ កំពង់តែដេកយប់ក៏ដោយថាយកសំបុត្រឲ្យគេ ខ្ញុំ មិនដែលប្រកែកទេ ។

សុខ វណ្ណៈ	ហើយយ៉ាងម៉េចទៅ?

សុខ គា:	គាត់ថា ឥឡូវអញយកឯងទៅលាក់ក្នុងចំការតា យ៉ង នៅខ្នារទទឹងស្គាល់ហើយឈ្មោះ តា យ៉ង ចឹងអញសុំគេមួយ ឯងគោមួយនឹមរទេះមួយសេះមួយនេះកុំឲ្យបាត់ណាថែផង យកខ្ញុំទៅលាក់នៅចំការតា យ៉ង កាលហ្នឹងសេះគាត់រទេះគោ គាត់ហ្នឹង ។

សុខ វណ្ណៈ	ឲ្យយកទៅធ្វើអី?

សុខ គា:	ឲ្យយកទៅថែ ដើម្បីលាក់ខ្ញុំ ចុះបើគេហៅឈ្មោះខ្ញុំយកទៅវៃចោលហើយ ដល់យកទៅ ដល់ចំការតា យ៉ង តា ឆេងប្រាប់ថាមើលក្មួយខ្ញុំឲ្យមែនទែន ប្រយ័ត្នតែបាត់ក្មួយខ្ញុំយក តា ឯងទៅវៃចោល ។

សុខ វណ្ណៈ	ចឹង តា ឆេងប្រាប់តា យ៉ងចឹង?

សុខ គា:	បាទ! តា ឆេងតាឲ្យតែបាត់ក្មួយខ្ញុំយកតាឯងទៅវៃចោលទាំងអស់ហ្នឹង គេថាចឹងមិនជា យ៉ាងណា គេថាមុខខ្ញុំ ។

សុខ វណ្ណៈ	ចឹងធ្វើម៉េចទៀត?

សុខ គា:	ចឹងទៅពេលខ្ញុំហូបបាយខ្ញុំនៅតែក្នុងខ្ទប ខ្ទបក្នុងផ្ទះ ។

សុខ វណ្ណៈ	ចឹងនៅជាមួយតា យ៉ងដល់ពេលណា?

សុខ គា:	ផុតពីនោះមកប្រហែលជាប៉ុន្មានខែ វារៀងស្ងាត់បានគាត់មកយកទៅវិញ យកបានប៉ុន្មាន ខែទៀត ខ្ញុំរត់សំបុត្រទៀត ខ្ញុំរត់សំបុត្រទៅដល់កន្លែងមេឈ្មោះ តា ផាន តា ព្រឿន ដល់នេះ គេស្គាល់ថា ចុះអានេះជានិរសាតា ឆេងគេយកទៅវៃចោលហើយ យ៉ាងម៉េច បានជានៅរស់វិញ មានអីគេដេញចាប់ខ្ញុំមួយសារទៀត ហើយខ្ញុំជិះសេះយ៉ាងលឿនមក

ចឹងខ្មាំរមកប្រាប់តា ឆេងវិញ ថាបង១ខ្ញុំយកសំបុត្រទៅឲ្យតា ដាន តា ព្រឿងគេតាម ចាប់ខ្ញុំទៀតហើយ ។ ចឹងតា ឆេងឲ្យខ្ញុំទៅកងចំការមួយទៀត តែភ្លេចឈ្មោះ គាត់ហើយ ខ្ញុំទៅហ្នឹងបានមួយអាទិត្យបានតា ឆេងទៅសុំរួលជាមួយមេៗគេ គាត់សុំរួលសុំខ្ញុំឲ្យនៅ គាត់ស្រណោះខ្ញុំថាជាកូនកំព្រា ។

សុខ វណ្ណៈ ចឹងពេលរត់សំបុត្រទៅដល់ឲ្យពីណាគេ?

សុខ គាៈ រត់សំបុត្រយកទៅឲ្យតា ដាននិង ព្រឿន ថា អានេះ និរសាតា ឆេង ត្រូវឈ្មោះយក វ៉ៃចោលហើយយ៉ាងម៉េចបានជានៅរស់ ដល់ហើយខ្ញុំជិះសេះទ្រឡប់មកវិញយ៉ាងលឿន តែនិរសាដូចគ្នានោះវាស្រណោះខ្ញុំដែរ ។

សុខ វណ្ណៈ ចឹងដល់ប្រាប់តា ឆេង តា ឆេងយកទៅលាក់ទៀត?

សុខ គាៈ បាទ! ទៅលាក់ទៀតបានប្រហែលជាកន្លះខែដែរ ។

សុខ វណ្ណៈ ចឹងបាននៅជាមួយតា ឆេងវិញ?

សុខ គាៈ បាទ! នៅជាមួយតា ឆេងវិញនៅជុំគ្នារាល់ថ្ងៃហើយតា ឆេងបានទៅសុំគេឲ្យខ្ញុំបាន កុំអី គេយកខ្ញុំវ៉ៃចោល បើដុតជំហានទី១ក៏ទី២ដែលដឹងតែយកទៅហើយ ។

សុខ វណ្ណៈ ចឹងក្រោយពីតា ម៉ុកមកប្រកាសបាត់ខ្លួនតា ឆេងទៅពូទៅនៅណាវិញ?

សុខ គាៈ កាលហ្នឹងគេឲ្យខ្ញុំទៅនៅជាមួយកងពលតា ម៉ុកវិញ ។

សុខ វណ្ណៈ ចឹងកងពល តា ម៉ុកហ្នឹងលេខប៉ុន្មាន?

សុខ គាៈ កាលនោះខ្ញុំមិនសូវដឹងទេ ព្រោះទើបបានចូលថ្មី ។

សុខ វណ្ណៈ ប្រធានកងពលពីណាគេ?

សុខ គាៈ ប្រធានកងពលតា ម៉ុកហ្នឹងហើយ ។

សុខ វណ្ណៈ តា ម៉ុក ជាប្រធានភូមិភាគ ។

សុខ គាៈ កាលហ្នឹងខ្ញុំមិនសូវដឹងទេ ខ្ញុំមិនសូវស្គាល់គេផង កាលគេហ្នឹងយកភ្លាមៗមិនសូវដឹង មិន ដឹងពីណាមេធំពីណាមេតូចមិនហ៊ានសួរគេទេ ។

សុខ វណ្ណៈ ចឹងកាលនៅជាមួយក្រុមតា ម៉ុកហ្នឹងមានបានទៅឡើងវ៉ៃជាមួយវៀតណាមទៀតទេ?

សុខ គាៈ អត់ទេ ។

សុខ វណ្ណៈ ចឹងនៅរហូតដល់បែកឆ្នាំ៧៩តែម្តង?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងនៅជាមួយតា ម៉ុកហ្នឹងនៅក្នុងខេត្តពោធិសាត់ហ្នឹងដដែល?

សុខ គា៖ នៅខេត្តពោធិសាត់ហ្នឹងដដែល នៅលើភ្នំបាក់ គេហៅភ្នំបាក់នៅជាមួយ តា ផែនអ៊ី តា ផែនហ្នឹងមានដីរ៉ៃពីរដឹកជញ្ជូនទៅ ។

សុខ វណ្ណៈ ចឹងដល់ថ្ងៃ៧មករាវៀតណាមចូលមកនេះ?

សុខ គា៖ កាល៧៩ហ្នឹងខ្ញុំរត់ទៅភ្នំកែវ ភ្នំបាក់ឡើងភ្នំចុះភ្នំ និយាយឲ្យវែងប្រាំសន្ទឹកទៀតមិនអស់ផង ។

សុខ វណ្ណៈ ចឹងពូនិយាយត្អីដែលខ្ញុំបានសួរចុះ?

សុខ គា៖ បាទ!ដាក់កន្លែងនេះផង កាលហ្នឹងតាឆេង ជួយរកម៉ែឪឲ្យផង ។

សុខ វណ្ណៈ ចឹងតា ឆេងជួយរកម៉ែឪឲ្យ?

សុខ គា៖ បាទ!ពេលខ្ញុំនៅវ៉ារថភ្លើងហ្នឹងណាស់ កាលហ្នឹងមិនដឹងគេដឹកប្រជាជនពីណាមកទេ គេឈប់ពោធិសាត់ហ្នឹង កាលហ្នឹងដឹងថាដឹកពីកើតមក ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ ប្រជាជនទាំងបារ៉ុនៗ គាត់ថា អា គាឯងរើតៗមើលក្រែងលោកឃើញម៉ែឯង ខ្ញុំក៏ឆ្លើយថា ចុះបើឃើញម៉ែខ្ញុំធ្វើម៉េចបង តែបើឃើញម៉ែឯងអញទៅសុំយកមកនៅជាមួយអញ ដល់ចឹងខ្ញុំខំដើររក កាលហ្នឹងខ្ញុំស្លៀកខោអាវខ្មៅពាក់ពួកខ្មែរក្រហមគេហ្នឹង ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ កាលហ្នឹងមានអីមានតែខោអាវខ្មៅហ្នឹង ។

សុខ វណ្ណៈ ចឹងកាលហ្នឹងបែបគេជម្លៀសមក?

សុខ គា៖ ជម្លៀសមកពីកើតហ្នឹងបើមិនកំពង់ឆ្នាំងមកពីខាងភ្នំពេញ កាលហ្នឹងមួយខ្សែមិនមែនតិចបារ៉ុនឯណា ចុះគេឲ្យឈប់ហ្នឹង ឈប់នៅក្រោមដើមស្វាយជាប់វ៉ាហ្នឹងពេញ ខ្ញុំចេះតែដើរមើល កាលហ្នឹងខ្ញុំហៅញោមៗ ខ្ញុំថាញោមមានឃើញឈ្មោះនេះៗចឹងទៅ ហើយតាឆេងហ្នឹងគាត់ថា បើឃើញប្រាប់អញ ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ អញទៅយកមក ខ្ញុំថាបានជួយម៉ែខ្ញុំឲ្យនៅជាមួយបងឯងហ្នឹង បងឯងឲ្យខ្ញុំធ្វើអីក៏ខ្ញុំធ្វើដែរ ខ្ញុំធ្វើមិនខ្វាចហត់ទេ មួយថ្ងៃៗ ខ្ញុំទៅនៅជាមួយគេសម័យប៉ុល ពតហ្នឹងខ្ញុំធ្វើមិនខ្វាចហត់ទេ ព្រលឹមឡើងមិនបាច់ប្រើខ្ញុំទេ ខ្ញុំមានទឹកឲ្យគេអស់ ។

សុខ វណ្ណៈ ចឹងកាលដែលពូនៅជានិរសា ពូមានឃើញប្រជាជនលំបាកទេ កាលហ្នឹង?

សុខ គា៖ និយាយរឿងលំបាក វាលំបាកណាស់ ។

សុខ វណ្ណៈ    លំបាកហូបចុក?

សុខ គាៈ    លំបាកហូបចុក លំបាកទាំងដេក ។

សុខ វណ្ណៈ    ចឹងមានដឹងថាគេសម្លាប់ប្រជាជនទេ?

សុខ គាៈ    ដឹងថាមានសម្លាប់ តែខ្ញុំមិនបានដឹងថាគេយកទៅសម្លាប់កន្លែងណាខ្លះ បើខ្ញុំកាលហានឹងគេយកទៅដែរ តែបានតា ឆេងជួយហើយ កុំបានតា ឆេងជួយខ្ញុំងាប់ហើយ ។

សុខ វណ្ណៈ    ចឹងកាលហ្នឹងពូបានឃើញទិដ្ឋភាពច្បាស់លាស់ហើយថា ប្រជាជននៅសហករណ៍គ្មានបាយហូបមនុស្សស្គមស្គាំង ឃើញមនុស្សស្លាប់ដោយសារអត់អាហារទេ?

សុខ គាៈ    មានឃើញ បើនៅក្នុងពេទ្យងាប់ច្រើនតើ នៅពេទ្យរំលេចខ្សារទទឹងហ្នឹងអត់បាយអត់ទឹកងាប់ច្រើន ជួនអីងាប់ដាក់តែរទេះយកទៅចោល មិនបានធ្វើបុណ្យទានទេ ជួយមិនរួចខ្ញុំកាលហ្នឹងលំបាកដែរ តែលំបាកតិច ពិបាកបំរើគេរៀងអត់ស៊ីមិនអីទេ ។

សុខ វណ្ណៈ    ចឹងប្រជាជនងាប់គ្មានបុណ្យទាន ងាប់ដូចខ្មោចឆ្កែឆ្មាចឹង?

សុខ គាៈ    បាទ!ងាប់លើកដាក់រទេះយកទៅកប់ចោលទៅ ។

សុខ វណ្ណៈ    ចឹងខ្ញុំចង់សួរត្រឡប់ទៅឆ្នាំ៧៩វិញ ពូរត់ទៅភ្នំកែវភ្នំបាក់បានប៉ុន្មានខែត្រឡប់ចូលភូមិវិញ ?

សុខ គាៈ    ប្រហែលជាពីរខែ ចូលភូមិវិញ ។

សុខ វណ្ណៈ    យ៉ាងម៉េចបានជាពូរត់ចូលព្រៃ?

សុខ គាៈ    ចុះកាលហ្នឹងយួនដេញ កាលខ្ញុំនៅជាយោធាខ្មែរក្រហម លែងជានិរសាហើយ ។

សុខ វណ្ណៈ    ចឹងនៅពេលដែលចូលភូមិវិញប្រជាជនមិនបានខឹងពូដែលធ្លាប់ធ្វើជានិរសាឲ្យតាឆេងទេ?

សុខ គាៈ    អត់មានទេ ។

សុខ វណ្ណៈ    ចឹងពូនៅក្នុងភូមិវិញរយៈពេលប៉ុន្មាន បានពូចូលបំរើឲ្យខ្មែរក្រហមវិញទៀត?

សុខ គាៈ    កាលហ្នឹងខ្ញុំនៅក្នុងភូមិបានប្រហែលជាកន្លះឆ្នាំទេ ខ្ញុំចូលបំរើឲ្យខ្មែរក្រហមនៅភ្នំឆត្រវិញ ខ្ញុំ មករកស៊ីបានមួយឆ្នាំបានខ្ញុំចូលធ្វើខ្មែរក្រហម កុំអីខ្ញុំក៏មិនចូលធ្វើខ្មែរក្រហមដែរ តែដោយសារចោរប្លន់ ។

សុខ វណ្ណៈ    ចឹងចូលខ្មែរក្រហមវិញនៅឆ្នាំណា?

សុខ គាៈ    កាលហ្នឹងចូលប្រហែលជាឆ្នាំ៨០ហើយ ។

សុខ វណ្ណៈ    ចឹងចូលខ្មែរក្រហមវិញដោយសារចោរប្លន់?

សុខ គា៖ បាទ! ចោរបួនយកមាសខ្ញុំឡើងម៉ត់មាសមានចន្តិចបន្តួចហ្នឹងប្រហែលជា៥ជីហ្នឹង ។

សុខ វណ្ណៈ ចូលមកភ្នំឆត្រហ្នឹងកងពលប៉ុន្មាន?

សុខ គា៖ កងពល១១៩ ។

សុខ វណ្ណៈ ចឹងប្រធានកងពលពីណាគេ?

សុខ គា៖ ប្រធានកងពល តា សារឿន ។

សុខ វណ្ណៈ ហើយមានពីណាទៀត?

សុខ គា៖ មាន តា ស៊ូ មាន តា វ៉ូយ តា ថែម ។

សុខ វណ្ណៈ ចឹងពូនៅជាមួយខ្មែរក្រហមបានប៉ុន្មានបានជាពូទៅធ្វើប៉ារាទៀត?

សុខ គា៖ ខ្ញុំមិនបានធ្វើទាហានប៉ារាទេ ខ្ញុំធ្វើទាហានខាងក្នុង ។

សុខ វណ្ណៈ ចឹងឆ្នាំណាបានទៅធ្វើទាហានខាងក្នុងវិញ?

សុខ គា៖ ចាំមើលខ្ញុំធ្វើខ្មែរក្រហមរបូត ខ្ញុំដើរវៃពេញមួយខេត្តបន្ទាយមានជ័យ កាលហ្នឹងខ្ញុំនៅមេដែរ ។

សុខ វណ្ណៈ ចឹងពូមានតួនាទីត្រឹមណា?

សុខ គា៖ ខ្ញុំជាប្រធានក្រុម ។

សុខ វណ្ណៈ ចឹងពីឆ្នាំ៨០ដល់ឆ្នាំណាបានឈប់ធ្វើជាមួយខ្មែរក្រហម?

សុខ គា៖ ខ្ញុំកាលហ្នឹងឆ្នាំ៨៤ ដល់ឆ្នាំ៨៥ខ្ញុំទៅនៅស្វាយចេក ដល់គេវៃខ្ទាំងគេរើសខ្ញុំទៀត ខ្ញុំប្រាប់ គេថាខ្ញុំជាអតីតខ្មែរក្រហម ខ្ញុំប្រាប់គេទៅគេនៅតែយកខ្ញុំទៀត ។

សុខ វណ្ណៈ ចឹងដល់ឆ្នាំ៨៥ ចូលខាងទាហានសាធារណរដ្ឋវិញ?

សុខ គា៖ ខ្ញុំចូលធ្វើទាហានហ៊ុន សែន ។

សុខ វណ្ណៈ ចឹងកាលនៅតំបន់ស្វាយចេកហ្នឹង ជាសមរភូមិក្តៅ?

សុខ គា៖ បាទ!ជាសមរភូមិក្តៅស្វាយចេក ។

សុខ វណ្ណៈ ចឹងនៅកន្លែងនេះមានភូមិមានប្រជាជនដងចឹងហើយសង្គ្រាមនៅក្នុងហ្នឹង តើប្រជាជនមាន គ្រោះថ្នាក់ទេ?

សុខ គា៖ មានគ្រោះថ្នាក់ទាំងប្រជាជនទាំងទាហាន កាលហ្នឹងប្រជាជនរើផ្ទះសំបែងមកនៅស្វាយច្រើនណាស់ ។

សុខ វណ្ណៈ ចឹងនៅស្វាយចេកហ្នឹងវាលទេ មិនសូវមានព្រៃទេ?

សុខ គា៖ នៅស្វាយចេកនេះមានផ្ទះច្រើនណាស់ ។

សុខ វណ្ណៈ ចឹងនៅពេលខ្មែរក្រហមវៃជាមួយទាហានវៀតណាមចឹងទៅ ពេលហ្នឹងប្រជាជនរត់តាមកង ទ័ពឬមួយ នៅក្នុងត្រង់សេក្រោមផ្ទះ?

សុខ គា: ជួននៅត្រង់សេផង រត់ចេញផង ណារត់មិនទាន់ក៏មានគ្រោះថ្នាក់ស្លាប់ទៅ តែភាគច្រើន គេចេញមុន គេដឹងច្បាស់ តែវៃមិនដឹងខ្លួនស្លាប់ច្រើនទៅ ។

សុខ វណ្ណៈ កាលឆ្នាំ៨៥ ពូចូលជាមួយទាហានហ៊ុន សែន វៃជាមួយទាហានខ្មែរក្រហមនិងទាហាន ប៉ុរាពមានបីភាគី?

សុខ គា: បាទ!មានបីភាគី ខ្ញុំកាលហ្នឹងមកវៃខ្មែរក្រហមប៉ុរាវិញ កាលហ្នឹងខ្ញុំនៅកងពល«១-៧៩»មានគ្រូចហេង កាន់«ង១១» ។

សុខ វណ្ណៈ គ្រូចហេង?

សុខ គា: បាទ! គ្រូច ហេងជាប្រធានវរៈ ។

សុខ វណ្ណៈ ចឹងប្រធានកងពល?

សុខ គា: ប្រធានកងពលតា ម៉េង ។

សុខ វណ្ណៈ ចឹងតាម៉េងគាត់ធ្វើអីឥឡូវ?

សុខ គា: តា ម៉េងគាត់ស្លាប់ហើយ ។

សុខ វណ្ណៈ ចឹងកាលពូនៅឆ្នាំ១៩៨៥ហ្នឹង កាលហ្នឹងមានទាំងកំលាំងវៀតណាមនិងកំលាំងហ៊ុន សែន មែនទេ?

សុខ គា: បាទ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងទាហានវៀតណាមនិងទាហានហ៊ុន សែនហ្នឹងមានដែលចាប់បានទាហានខ្មែរ ក្រហមនិងទាហានប៉ុរាទេ?

សុខ គា: ចាប់បានគ្នាទៅវិញទៅមក ភាគច្រើនយើងចាប់បានច្រើនជាង ។

សុខ វណ្ណៈ ចឹងនៅពេលចាប់បានហ្នឹងយកទៅណាវិញ?

សុខ គា: យកទៅដាក់គុកភ្នំពេញដឹង ។

សុខ វណ្ណៈ ចឹងកាលហ្នឹងអត់មានសម្លាប់ទេ?

សុខ គា: មិនមានទេ កាលហ្នឹងគេថាជាឈ្លើយសឹក វាចាប់បានយើងក៏មិនសម្លាប់យើង ។

សុខ វណ្ណៈ ចឹងបើទាហានខ្មែរក្រហមចាប់បានទាហានហ៊ុន សែននិងទាហានវៀតណាមមានសម្លាប់ទេ ?

សុខ គា៖ ចាប់បានមិនមានសម្លាប់ដូចតែគ្នា គេចាត់ទុកជាឈ្លើយសឹក បើខ្មែរក្រហមចាប់បានចឹង គេយកទៅឲ្យមេធំៗទៅ ចាប់ឈ្លើយសឹករឿងសម្លាប់ចោលមិនបានទេ លៀសតែសម័យ ប៉ុល ពតទេ ដែលគេយកទៅសម្លាប់ចោល តែបើចាប់សម័យនេះមិនមានយកវៃចោល ទេ គេចាប់ទៅយកទៅដាក់គុក ខ្លះគេប្រើបានធ្វើជាទាហានទៀត នៅប៉ារាខ្លះអីដែលចាប់ បានយកទៅធ្វើជាទាហាន ដល់គេដាក់គុកយូរៗនៅរស់ដូចដែលយើងចឹង ។

សុខ វណ្ណៈ ចឹងលើកលែងតែបាញ់គ្នាស្លាប់ទេ?

សុខ គា៖ បាទ!លើកលែងតែបាញ់គ្នាស្លាប់ទេ បើសម័យប៉ុល ពតបើចាប់បានមានតែវៃចោល ដល់សង្គមនេះគេរកតែមនុស្សច្បាំងរឿងសម្លាប់ចោលគេមិនសម្លាប់ទេ បើចឹងខ្ញុំអតីតខ្មែរ ក្រហមដែរ ។

សុខ វណ្ណៈ ចឹងកាលពូនៅធ្វើខ្មែរក្រហមមានជំនួយមកពីខាងណា?

សុខ គា៖ មានជំនួយមកពីចិន ។

សុខ វណ្ណៈ ចឹងនៅពេលដែលមកធ្វើទាហានជាមួយហ៊ុន សែនវិញ ជំនួយ?

សុខ គា៖ កាលហ្នឹងជំនួយអាវុធអីមានតែមកពីខាងសូវៀត ។

សុខ វណ្ណៈ ចឹងផ្ទះនៅស្វាយចេកកាលពីមុនមិនមានធំដូចឥឡូវទេ?

សុខ គា៖ ផ្ទះកាលហ្នឹងមានតូចខ្លះធំខ្លះ តែផ្ទះធំហ្នឹងវាមានតិច ។

សុខ វណ្ណៈ ចឹងកាលនៅស្វាយចេកហ្នឹងមានភ្លើងឆេះដោយសារសង្គ្រាមច្រើនដងណាស់?

សុខ គា៖ កាលហ្នឹងឆេះជាញឹកញាប់ណាស់ ទាំងផ្ទះខ្ញុំផ្ទះគេ ចុះកាលហ្នឹងជាសមរភូមិក្តៅនោះ ម៉ា កម្ពុជាយើងនៅស្វាយចេកខ្លាំងណាស់និងភ្នំស្រុកជាសមរភូមិក្តៅ ក្រៅពីហ្នឹងមិនសូវទេ ស្វាយចេកជាសមរភូមិក្តៅ ព្រោះជាតំបន់ខ្លាំងដែលលាក់ខ្លួននៅខាងជាយដែននេះ ។

សុខ វណ្ណៈ ចឹងពូនៅជាទាហានហ៊ុន សែនរហូតដល់ពេលណាបានឈប់?

សុខ គា៖ ខ្ញុំឈប់នៅពេលដែលខ្ញុំត្រូវគ្រាប់ ។

សុខ វណ្ណៈ ចឹងពូត្រូវគ្រាប់នៅពេលណា?

សុខ គា៖ ខ្ញុំត្រូវគ្រាប់នៅឆ្នាំ៨៨-៨៩ ។

សុខ វណ្ណៈ ចឹងពេលហ្នឹងវៀតណាមដកអស់ហើយនៅ?

សុខ គា៖ នៅ ។

សុខ វណ្ណៈ តែវៀតណាមដកតាំងពីឆ្នាំ៨៧នោះ?

សុខ គា៖ បាទ! គេដកនៅឆ្នាំ៨៧ ខ្ញុំនៅបានមួយឆ្នាំហើយបានត្រូវ ប្រហែលជាឆ្នាំ៨៨ ។

សុខ វណ្ណៈ ចឹងកាលដែលវៀតណាមដកហ្នឹងពិតប្រាកដទេ?

សុខ គា: បាទ!ដកមែនដកមែនខ្ញុំទៅនៅកន្លែងវា នៅដូនភក់ស្វាយចេកនោះ កាលហ្នឹងនៅមានចំនាញការមួយៗ ។

សុខ វណ្ណៈ ចឹងនៅសល់ខ្មែរវៃខ្មែរ?

សុខ គា: គេដកអស់ហើយនៅជំនាញការមួយៗ ។

សុខ វណ្ណៈ ចឹងជំនាញការវៀតណាមហ្នឹងអស់នៅពេលណា?

សុខ គា: អស់នៅឆ្នាំ៨៩-៩០នេះហើយ ដល់៩១ខ្ញុំត្រឡប់មកពីវៀតណាមវិញហើយ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងពូទៅព្យាបាលនៅវៀតណាម?

សុខ គា: បាទ!ទៅព្យាបាលនៅវៀតណាម ខ្ញុំនៅព្យាបាល៥ខែនៅសៃហ្គន កាលហ្នឹងខ្ញុំត្រូវគ្រាប់គេដឹកខ្ញុំទៅមន្តលបូរី គេថាយន្តហោះមកយកនៅមន្តលបូរីដល់មិនបានមកយកនៅមន្តល បូរីមកយកនៅខេត្តវិញខ្ញុំគេដាក់យន្តហោះទៅដល់ភ្នំពេញនោះ មានសក្តិ៣ ស្រីនោះ ជួយខ្ញុំ យកខ្ញុំទៅថ្ងៃសៅដល់ព្រលឹមឡើងថ្ងៃអាទិត្យមិនបានធ្វើការ ដល់ថ្ងៃច័ន្ទនោះខ្ញុំខឹង គេដង់សក្តិ៣នោះកាលហ្នឹងប្តីគាត់បើកយន្តហោះប្រពន្ធពាក់សក្តិ៣នៅហ្នឹង កាលហ្នឹង ពេទ្យ“១-៧៩” ។

សុខ វណ្ណៈ បាទ ។

សុខ គា: អ្នកស្រីមកនិយាយថាលោកឯងនៅណា?ខ្ញុំប្រាប់ថាខ្ញុំនៅខេត្តបន្ទាយមានជ័យ មានប្រពន្ធអត់? ថាប្រាប់ថាខ្ញុំមាន ហើយប្រាប់ថាមិនឲ្យខ្ញុំគិតរឿងប្រពន្ធកូនទេ ខ្ញុំថាហេតុអីមិនឲ្យខ្ញុំគិត គេថាបើលោកឯងគិតមិនជាទេ លោកឯងវារៀងធ្ងន់បន្តិច កាលហ្នឹងត្រូវពេញខ្លួន គាត់ឲ្យគេកាត់អាវខោអស់ឈាមជោគរហាមដូចជាអណ្តូងចេញទឹក ។

សុខ វណ្ណៈ បាទ ។

សុខ គា: កាលហ្នឹងអ្នកស្រីទៅទិញទឹកដូងឲ្យខ្ញុំផឹក កាលហ្នឹងខ្ញុំមានលុយតែប៉ុន្មាន កាលហ្នឹងមាន៣០០០០ខ្មែរយើងហ្នឹងណាស់ អ្នកស្រីហ្នឹងគាត់ចិត្តបានណាស់គាត់ទិញនេះទិញនោះឲ្យខ្ញុំប្រាប់ខែរៀបទៅវៀតណាមបើឲ្យខ្ញុំ៥ខែទៀត ។ មុនទៅវៀតណាមស្មៀកពាក់ឲ្យខ្ញុំហើយបានគេបញ្ជូនទៅ បញ្ជូនទៅសៃហ្គនកាលហ្នឹងព្យាបាលនៅវៀតណាម៥ខែ បន្ទប់ខ្ញុំដេកនោះ“បេ៩” ។

សុខ វណ្ណៈ ចឹងកាលហ្នឹងវៀតណាមយកចិត្តទុកដាក់ទេ?

សុខ គា៖ បាទ! វៀតណាមយកចិត្តទុកដាក់ណាស់ កាលហ្នឹងខ្ញុំហូបផ្តេះផ្តាស់ខ្ញុំរាគអីផ្លាស់ឲ្យខ្ញុំ គេបោកគ្លួកឲ្យខ្ញុំរហូត គេយកចិត្តទុកដាក់ណាស់ ខ្ញុំមិនភ្លេចគុណគេទេ កាលហ្នឹងគេមិនឲ្យខ្ញុំមកផង តែខ្ញុំចេះតែខ្លាច កាលខ្ញុំទៅនោះសុទ្ធតែអ្នកពាក់សក្តិធំៗណាស់ បើនៅកងពលបានទៅដល់ បើទាហានស្រុកមិនបានទៅទេ ឲ្យឈ្មោះថា នៅកងពលទោះបីកងពលលេខ ប៉ុន្មានក៏ដោយ កងពលខេល២ កងពលលេខ៦ លេខ៣ក៏ដោយបានដល់វៀតណាម បើ ទាហានស្រុកព្យាបាលតែភ្នំពេញទេ ។ កាលហ្នឹងខ្ញុំសុំគេវះនៅភ្នំពេញគេមិនសុខចិត្តផង គេ ថាលោកឯងត្រូវតែទៅវៀតណាម នៅពេលដែលទៅដល់វៀតណាម វៀតណាមសួរ ទៀតថា អីណាបងប្អូនព្រោះគេត្រូវការវះខ្ញុំ ខ្ញុំថាអត់មានទេ ខ្ញុំជាកូនកំព្រាទេ ដល់ ពេលចឹងគេមិនហ៊ានវះខ្ញុំទេព្រោះគេខ្លាចមានគ្រោះថ្នាក់គេបន្ទោស ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ ខ្ញុំថាធ្វើម៉េចធ្វើទៅទុកតែឆ្អឹងឲ្យប្រពន្ធខ្ញុំបានហើយ វះទៅបើខ្ញុំស្លាប់ដុតខ្ញុំទុកឆ្អឹងមួយកញ្ចប់សរសេរឈ្មោះ យកទៅឲ្យប្រពន្ធខ្ញុំ នៅខេត្តបន្ទាយមានជ័យ ស្រុកនេះ ឃុំនេះខ្ញុំសរសេរឲ្យស្រេច ដល់ចឹងគេហ៊ានវះខ្ញុំ ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ កាលហ្នឹងនៅភ្នំពេញគេមិនហ៊ានវះ កាលនៅភ្នំពេញដុកទ័ពធំៗនៅភ្នំពេញមិនហ៊ានវះ ខ្ញុំឲ្យគេវះនៅទីនេះហើយ ស្រួលខ្ញុំហៅប្រពន្ធខ្ញុំមក គេថាអត់បានគេ លោកឯងត្រូវតែទៅដល់ទៅដល់វៀតណាម គេមកសួរទៀតសុទ្ធតែដុងទ័រធំៗ ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ ហ្នឹងហ្នឹងវះខ្ញុំមិនដឹងជាយកទៅចូលម៉ាស៊ីនដឹងជាប៉ុន្មានដង ថាយើងត្រូវវះថ្ងៃណាបាន ទំរាំវះខ្ញុំបីដង ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ គេយកទៅមើលម៉ាស៊ីនចេះគេថា មិនកើតហើយគេប៉ូវឲ្យខ្ញុំហូបអានេះអានោះ កាលហ្នឹងខ្ញុំមិនក្រោកបានទេ ខ្ញុំនៅតែលើគ្រែទេ តែគ្រែបត់បានពីរបីជាន់ ។

សុខ វណ្ណៈ បាទ ។

សុខ គា៖ គេរុញខ្ញុំដើរលេងឲ្យល្ហើយអីចឹងទៅ គេឲ្យយើងហូបឲ្យឆ្អែតគេមើលថែយើងណាស់ ។

សុខ វណ្ណៈ ចឹងខ្ញុំចង់សួរពូ កាលហ្នឹងពូរៀបការនៅឆ្នាំណា?

សុខ គា: ខ្ញុំរៀបការនៅឆ្នាំ១៩៨៤ហើយ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងពូនៅតំបន់ខ្មែរក្រហមឡើយ?

សុខ គា: បាត!ខ្ញុំនៅខ្មែរក្រហមនៅឡើយដល់៨៥ខ្ញុំទៅនៅស្វាយចេក ។

សុខ វណ្ណៈ ចឹងប្រពន្ធក្រោយពូយកនៅឆ្នាំណា?

សុខ គា: ប្រពន្ធក្រោយនេះខ្ញុំយក ដោយសារប្រពន្ធមុនធ្វើបាបចិត្តខ្ញុំគេទៅយកប្ដីទៀត គេទៅចឹងកកគេបានប្ដីទៀត ខ្ញុំនៅជាមួយកូន កូនវាបំរើមែន តែវាមិនដូចប្រពន្ធឯងដូចនេះខ្ញុំយក ទៀតទៅ គេក្មេងខ្ញុំអស់លុយច្រើនណាស់បានគេហ្នឹង ។

សុខ វណ្ណៈ ចឹងសព្វថ្ងៃគាត់នៅហឹងដែរ?

សុខ គា: នៅ ។

សុខ វណ្ណៈ ចឹងមិនអីទេ ជួយមើលថៃពូដែរ?

សុខ គា: បាទ!កូនខ្ញុំនៅចឹងកក កូនស្រីខ្ញុំ ។

សុខ វណ្ណៈ បាទ ។

សុខ គា: កូនស្រីហ្នឹង ព្រះអង្គសេរីវុឌ្ឍជួយទៀតនោះ តែវាមិនដុះស្នួរអ្នកភូមិនេះបានដឹង ។

សុខ វណ្ណៈ បាទ ។

សុខ គា: កាលខ្ញុំនៅផ្ទះតូច ផ្ទះនេះកូនខ្ញុំវាខំរកបានធ្វើទេ គ្មានពីណាឲ្យទេ កាលហ្នឹងព្រះអង្គសេរីវុឌ្ឍ ចុះមកជួយធ្វើស្រះចឹងទៅ កាលហ្នឹងខ្ញុំស្គាល់តាមខ្សែរយៈញឹក ប៊ុនឈុន គាត់ជាអភិ បាលរងទី១ ។

សុខ វណ្ណៈ បាទ ។

សុខ គា: កាលមុនមិននៅស្វាយចេកជួបខ្ញុំ កាលហ្នឹងគាត់ជាគ្រូបង្រៀនទេ ។

សុខ វណ្ណៈ បាទ ។

សុខ គា: ដល់គាត់ជិះឡានតាមនេះមក គាត់ឃើញខ្ញុំ គាត់ថាឯងនេះឯង ខ្ញុំឆ្លើយថាបាទ ដល់ចឹងគាត់ថាអញទៅភូមិរៀនមួយភ្លេតចាំអញមកវិញ ដល់មកវិញព្រះអង្គសេរីវុឌ្ឍគង់ក្នុងឡាន ថ្ងៃហ្នឹងកូនស្រីខ្ញុំកាលហ្នឹងវារៀនតែព្រឹក ល្ងាចវាអត់រៀន ។

សុខ វណ្ណៈ បាទ ។

សុខ គា: ដល់ចឹង ញឹក ប៊ុនឈុនឈប់នៅមុខផ្ទះខ្ញុំ ដល់ហើយគាត់ចុះមកខ្ញុំជិរាបសួរគាត់ កូនខ្ញុំក៏ចេញមកពុឡានេនោះ កូនស្រីខ្ញុំនៅដាំបាយ កូនខ្ញុំនោះចេញមកជិរាបសួរគ្រប់សុទ្ធតែអ្នក

ធំៗនោះ ដល់ចឹងទៅព្រះអង្គសេរីវុឌ្ឍឃើញ ចុចកញ្ចក់សួរថាកូនឯងនៅរៀនអត់ កូនខ្ញុំឆ្លើយថាលោកតូ ខ្ញុំនៅរៀនរាល់ថ្ងៃ កាលពិតមិនបានដឹងថាព្រះអង្គសេរីវុឌ្ឍទេ ។

សុខ វណ្ណៈ បាទ ។

សុខ គា: ចឹងបើកូនឯងនៅរៀនឪជួយម៉ារហូត គិតទៅថាបានកប់ពពកហើយតែបែជាមិនបានវិញ វាឆាប់យកប្តី វាស្រឡាញ់គ្នា កាលហ្នឹងព្រះអង្គសេរីវុឌ្ឍទៅមកៗៗគេឲ្យលុយសុទ្ធតែដូល្លាឲ្យចឹងទៅ ចឹងកាលហ្នឹងព្រះអង្គសេរីវុឌ្ឍឲ្យកូនខ្ញុំដើរកក់ក្នុងភូមិនេះមានចាស់ៗប៉ុន្មាន? កូនខ្ញុំវាដើរកក់មែន កក់ហើយព្រះអង្គសេរីវុឌ្ឍឲ្យលុយចែកចាស់ៗ ហើយព្រះអង្គសេរីវុឌ្ឍប្រាប់ញឹក ប៉ុនឈុនឲ្យមើលកូនខ្ញុំផង គេដាក់ឈ្មោះថា កូនគេហើយតែកូនខ្ញុំវាមិនមានកំណើតតែម្តង ។ បើកូនខ្ញុំមានកំណើតខ្ញុំមិនដឹងជាស្រួលយ៉ាងណាទេ ដល់កូនខ្ញុំយកគ្រួសារទៅព្រះអង្គឈប់ចិញ្ចឹមហើយ អូនឯងមានស្គាល់កន្លែងម៉ាតាំងដែលគេចិញ្ចឹមកូនក្មេងអូរអំបិលណាស់ ។

សុខ វណ្ណៈ បាទ ។

សុខ គា: សព្វថ្ងៃកូនខ្ញុំបើកបាននៅហ្នឹងហើយ កាលហ្នឹងខ្ញុំនៅអូរអំបិលគេជួយ ។

សុខ វណ្ណៈ ឥឡូវកូនតូទៅណាហើយ?

សុខ គា: អាមួយរៀននៅផ្ការំហ្នឹង ។

សុខ វណ្ណៈ ចឹងកូនស្រីដែលព្រះអង្គចិញ្ចឹមមុននោះទៅណាហើយ?

សុខ គា: នៅបឹងកកហ្នឹង បានប្តីព្រះអង្គឈប់ចិញ្ចឹមហើយ កាលខ្ញុំទៅស្វាយខ្ញុំគេទៅភ្នំពេញ កាលហ្នឹងព្រះអង្គនៅរដ្ឋសភា កាលហ្នឹងព្រះអង្គថាឯងមកមានការអី? ខ្ញុំថាព្រះអង្គកូនព្រះអង្គមានមូលហេតុហើយ វាស្រឡាញ់គ្នា ព្រះអង្គថា តាឯងខ្ញុំឲ្យកូនរៀនសិនឲ្យវាចេះទៅចិញ្ចឹមតាឯង ហៅខ្ញុំតែតា ។

សុខ វណ្ណៈ បាទ ។

សុខ គា: កូនចេះទៅចិញ្ចឹមតាឯង តាឯងគិតមើលខាងសៀមរាបខ្ញុំយកតែពីរទេ ហើយខេត្តបន្ទាយ មានជ័យហ្នឹង កូនសិស្សរាប់សែននាក់ខ្ញុំយកតែកូនតាឯងមួយទេ តាឯងដើរសួរទៅ តា ឯងម៉េចបានជាបណ្តោយកូនចឹង ខ្ញុំឆ្លើយជាមួយព្រះអង្គមិនរួចទេ បើកុំតែដើងខ្ញុំបាក់ទេ ខ្ញុំយកកូនខ្ញុំឲ្យទៅនៅភ្នំពេញហើយ ប្រគល់ឲ្យព្រះអង្គហើយ ។

សុខ វណ្ណៈ បាទ ។

សុខ គា: ចឹងព្រះអង្គប្រាប់ថាឲ្យម៉ែឪខាងប្រុសមកភ្ជាប់ពាក្យជាមួយញោមទៅ ។

សុខ វណ្ណៈ ចឹងខ្ញុំសូមកាត់សាច់រឿងចេញបន្តិចចេញ ព្រោះវាមិនសូវទាក់ទងសាច់រឿងនេះទេ ។

សុខ គាៈ បាទៗ!អាហ្នឹងរឿងព្រះអង្គជួយ ។

សុខ វណ្ណៈ ចឹងរាល់ថ្ងៃនេះកូនហ្នឹងក៏បែកទៅ តែក្រោយមកបានជួយធ្វើផ្ទះសំបែងអីដែរ?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងបានផ្ញើរលុយកាក់ឲ្យពូដែរ?

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងមានន័យថាកូនហ្នឹងក៏មានចិត្តល្អដែរជាមួយពូ ។

សុខ គាៈ បាទ ។

សុខ វណ្ណៈ ចឹងខ្ញុំចង់សួររឿងទាក់ទងជាមួយតុលាការ ចឹងសព្វថ្ងៃនេះមានតុលាការកាត់ទោសមេដឹកនាំ ខ្មែរក្រហមហ្នឹង ពូគិតថាជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ?

សុខ គាៈ បើខ្ញុំពិចារណាខ្ញុំដេកស្តាប់ដែរ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ ដូចជាតា ឌុចអីហ្នឹងក៏ជាមេខ្ញុំពីដើមដែរ បើនិយាយទៅខ្ញុំមិនហ៊ានអាកាត់ទេ សូមណូមពរស្រេចតែលើប្រជាជន បើប្រជាជនថាខុះខ្សោយត្រង់ណាត្រង់ណីអាហ្នឹងតាមសូមណូមពរ ដែរ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ ខ្ញុំមិនហ៊ានអាកាត់ថា វាខុសត្រង់នេះត្រង់នោះ បើនិយាយទៅច្បាប់អស់រាប់ម៉ឺនទៅហើយ វាខ្វាំងហើយ បើនិយាយទៅអស់ប្រជាជនរាប់ម៉ឺនហើយ ដូចជាស្ពានពេជចឹងស្លាប់មនុស្ស អស់ច្រើន យកមួយម៉ឺនដុល្លាទៅឲ្យ វាមិនមែនមួយម៉ឺនដុល្លាទិញមនុស្សបានទេ តែធ្វើយ៉ាងម៉េចបើយើងគ្រោះថ្នាក់ទៅហើយ ដូចសម្តេចហ៊ុន សែនជួយមួយម៉ឺនហ្នឹងណាស់ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ មិនមែនយកលុយទៅទិញទេ តែធ្វើម៉េចបើយើងគ្រោះថ្នាក់ទៅហើយ ដូចជិនាន់ប៉ុលពត ហ្នឹងយកមនុស្សទៅវៃចោលវាអស់រាប់លានទៅហើយ ចឹងដូចជាឪពុកលម្តាយវៃកូនហើយត្រូវតែលួងកូនវិញ ចឹងមួយទៀតប្រជាជនអស់រាប់លានហើយគាត់ឈឺចាប់ណាស់

សូម្បីតែខ្ញុំ ចឹងជាខ្មែរក្រហមដែរ យកឪពុកម្ដាយខ្ញុំទៅវៃចោលអស់ហើយ ចឹងសួរថាខ្ញុំឈឺចាប់ទេ? ខ្ញុំឈឺចាប់ណាស់ តែមិនដឹងជាធ្វើយ៉ាងម៉េចបើវាខុសទៅហើយ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ តែការកាត់ទោសហ្នឹងឲ្យរួចខ្លួនវាមិនរួចទេ កាត់ទោសប៉ុន្មានថា៣៥ឆ្នាំហ្នឹង ។

សុខ វណ្ណៈ តែដោយសារជាប់នៅតុលាការយោធាផង គេឲ្យគាត់ជាប់តែជាង១០ឆ្នាំទៀតទេ ។

សុខ គាៈ បាត!នៅសល់១៩ឆ្នាំទៀតហ្នឹងវាមិនធូរទេ បើខ្ញុំពិចារណាទៅ១៩ឆ្នាំឲ្យរួចប្រជាជនបីលានវាមិនអាចបានទេ តែមិនដឹងជាធ្វើយ៉ាងម៉េចបើវាខុសទៅហើយ ។

សុខ វណ្ណៈ ចឹងកាលដែលឌុច ជាប់ទោសតែ១៩ឆ្នាំហ្នឹង ចឹងចិត្តពូអាចទទួលបានយុត្តិធម៌ដែលឬអត់ចិត្តពូវិញ?

សុខ គាៈ ខ្ញុំមានពីរផ្នែក ចិត្តនោះវាមិនគ្រប់គ្រាន់ទេ ចិត្តមួយទៀតគិតថាដាក់ច្រើនពេកទៅក៏វាអត់អំពើគាត់ចាស់ហើយ ទោះបីដាក់ច្រើនខ្មោចហ្នឹងងាប់ ទាល់តែដាក់ជីវិតខ្មោចហ្នឹងទៀត ។ ព្រោះឥឡូវដូចជា៧០ជាងហើយ ។

សុខ វណ្ណៈ បាទ ។

សុខ គាៈ អានេះបើនិយាយថាឲ្យរួចវាមិនរួចទេ ប្រជាជនគេខឹងខ្លាំងណាស់ ។

សុខ វណ្ណៈ ចឹងទោះបីចឹង យើងមានតុលាការដើម្បីកាត់ទោសអ្នកដែលបានធ្វើខុស ទោះបីគាត់មានវ័យចំណាស់យ៉ាងណា ចឹងតាមផ្លូវច្បាប់ត្រូវតែមានការកាត់ទោស ។

សុខ គាៈ បាទ!តាមច្បាប់អន្តរជាតិគេដឹងពូជង ។

សុខ វណ្ណៈ ចឹងទោះបីយ៉ាងណាពូអស់ចិត្តខ្លះដែរ?

សុខ គាៈ ខ្ញុំអស់ចិត្តហើយ ព្រោះឪពុកស្លាប់ដែរ បើម្ដាយខ្ញុំប្រហែលជាស្លាប់ដោយសារអត់អាហារ បើឪពុកខ្ញុំដឹងថាចាល់កលគេហើយ ។

សុខ វណ្ណៈ បាទ!ចឹងខ្ញុំអរគុណពូច្រើនហើយដែលបានផ្ដល់បទសម្ភាសន៍ ។

សុខ គាៈ បាទ ។

**ចប់**